# ស្ថានភាពអតិផរណានៅខែមេសា ឆ្នាំ២០១៦

*******

**ក/ អតិផរណាក្នុងប្រទេស**

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែមេសា ឆ្នាំ២០១៦ បានកើនឡើង **១,៥%** ធៀបនឹងខែកន្លងទៅ និងបានកើនឡើង **២,៨%** ធៀបនឹង១២ខែមុន។ នៅខែមេសា ឆ្នាំ២០១៦ សន្ទស្សន៍ថ្លៃនៃក្រុមទំនិញមួយចំនួនមានការកើនឡើងគួរឲ្យកត់សម្គាល់ធៀបនឹងខែមុនដូចជា សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងកើនឡើង ២,៤% ក្នុងនោះថ្លៃអង្ករកើនឡើង ១,០% ថ្លៃសាច់មាន់កើនឡើង ១,៧% ថ្លៃត្រីស្រស់កើនឡើង ២,៦% ថ្លៃបន្លែកើនឡើង ៧,៣% ថ្លៃផ្លែឈើកើនឡើង ៦,៥% និងសន្ទស្សន៍ថ្លៃសំលៀកបំពាក់និងស្បែកជើងកើនឡើង ១,៤% ដោយសារមានការកើនឡើងតម្រូវការប្រើប្រាស់ ក្នុងកំឡុងពេលប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ។ ប៉ុន្តែក្នុងនោះក៏មានសន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំបានថយចុះ ០,៨%ដែរ។

បើធៀបនឹង១២ខែមុន សន្ទស្សន៍ថ្លៃទំនិញមានការកើនឡើងជាពិសេស សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងបានកើនឡើង ៩,៨% ដោយសារការបង្កើនពន្ធអាករពិសេសលើផលិតផលទាំងនោះ។ សន្ទស្សន៍ថ្លៃម្ហូបអាហារបានកើនឡើង ៦,១% និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋានបានកើនឡើង ៤,៥% ដោយសារការធ្លាក់ចុះការផ្គត់ផ្គង់ផលិតផលម្ហូបអាហារក្នុងពេលមានការអូសបន្លាយនៃភាពរាំងស្ងួត និងបរិមាណផលិតកម្មម្ហូបអាហារមួយចំនួន នៅទាបជាងតម្រូវការនៃការប្រើប្រាស់។

ការប្រែប្រួលសន្ទស្សន៍ថ្លៃទាំង ១២ ក្រុម មានដូចខាងក្រោម÷

| | ធៀបខែមុន | ធៀប ១២ខែមុន |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **+១,៥** | **+២,៨** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +២,៤ | +៦,១ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +០,៨ | +៩,៨ |
| ៣-សំលៀកបំពាក់និងស្បែកជើង | +១,៤ | +៥,៥ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | +០,៤ | -៣,២ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | -០,៨ | +៣,២ |
| ៦-សុខាភិបាល | +០,៨ | +២,៩ |
| ៧-ការដឹកជញ្ជូន | +០,២ | -១០,២ |
| ៨-គមនាគមន៍ | +០,២ | +១,៦ |
| ៩-ការកំសាន្ត និងវប្បធម៌ | +០,១ | +៣,១ |
| ១០-ការសិក្សា | ០,០ | +០,៦ |
| ១១-ភោជនីយដ្ឋាន | +០,៣ | +៤,៩ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +១,៨ | -០,២ |

តាមការសង្កេតសន្ទស្សន៍ថ្លៃទំនិញនៅឆ្នាំ២០១៦នេះ អាចមានការកើនឡើងខ្លាំង ដែលបណ្តាលមកពីសំពាធនៃការកើនឡើងថ្លៃម្ហូបអាហារ កំណើនថ្លៃប្រេងឆៅអន្តរជាតិ និងពន្ធ។

| តារាង÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារ មួយចំនួនប្រចាំឆ្នាំ២០១៥-២០១៦ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ២០១៥ | | | ២០១៦ | | |
| | កុម្ភៈ | មីនា | មេសា | កុម្ភៈ | មីនា | មេសា |
| អង្ករ | 1.3 | 1.1 | 1.2 | 2.3 | 2.1 | 2.8 |
| សាច់គោ | 4.4 | 2.9 | 2.8 | 10.4 | 10.8 | 11.4 |
| សាច់មាន់ | 3.2 | 2.3 | 2.1 | 4.8 | 5.5 | 6.4 |
| សាច់ទា | 5.4 | 5.0 | 5.8 | 1.8 | 1.1 | 1.3 |
| សាច់ជ្រូក | 7.8 | 5.6 | 6.3 | 5.1 | 4.2 | 3.3 |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | 6.6 | 5.8 | 6.0 | 8.4 | 9.2 | 10.2 |
| ក្នុងនោះត្រីស្រស់ | 7.2 | 6.8 | 6.7 | 8.8 | 9.4 | 10.4 |
| ផ្លែឈើ | 7.1 | 4.3 | 3.0 | 3.6 | 3.9 | 8.7 |
| ផ្លែឈើស្រស់ | 8.4 | 5.4 | 4.2 | 3.7 | 3.5 | 9.2 |
| បន្លែ | 7.9 | 8.8 | 9.9 | 3.0 | 2.4 | 8.7 |
| បន្លែជាស្លឹក | 10.8 | 12.0 | 13.5 | -2.0 | -1.9 | 1.3 |
| បន្លែជាផ្លែ | 10.5 | 10.8 | 12.4 | 5.7 | 4.5 | 19.8 |

<u>**កំណត់សម្គាល់**</u>

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញចំនួន ២៥៩មុខ ដែលត្រូវបានជ្រើសរើស
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារទាំង ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ ក្នុងផ្សារនីមួយៗ
- សំរាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

## ៣/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

តារាងឧបសម្ព័ន្ធ៣÷ អតិផរណាប្រចាំឆ្នាំ (ជាភាគរយ)

| ប្រទេស | ២០១៥ | | | | ២០១៦ | | | |
|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | មករា | កុម្ភៈ | មីនា | មេសា |
| ប្រទេសកម្ពុជា | 0.4 | 1.6 | 1.1% | 1.3 | 3.0 | 2.3 | 2.0% | 2.8 |
| ប្រទេសវៀតណាម | 0.9 | 0.3 | 0.9% | 1.0 | -36.7 | -33.3 | -36.1% | -36.0 |
| ប្រទេសថៃ | -0.41 | -0.52 | -0.57% | -1.04 | -0.53 | -0.50 | -0.46% | 0.07 |
| ប្រទេសម៉ាឡេស៊ី | 1 | 0.09 | 0.91% | 1.82 | 3.53 | 4.19 | 2.61% | 2.14 |
| ប្រទេសឥណ្ឌូនេស៊ី | 6.96 | 6.29 | 6.38% | 6.79 | 4.14 | 4.42 | 4.45% | 3.60 |
| ប្រទេសភីលីពីន | 2.40 | 2.47 | 2.40% | 2.17 | 1.35 | 0.92 | 1.13% | 1.10 |
| ប្រទេសចិន | -1.66 | -0.59 | -0.98% | -0.29 | 0.99 | 0.89 | 0.89% | 0.79 |
| ប្រទេសកូរ៉េខាងត្បូង | 0.83 | 0.55 | 0.37% | 0.37 | 0.79 | 1.24 | 0.97% | 1.01 |
| ប្រទេសជប៉ុន | 2.38 | 2.18 | 2.28% | 0.58 | -0.10 | 0.29 | 0.00% | -0.29 |

កំណត់សម្គាល់÷ ប្រភពទិន្នន័យ(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**រៀបចំ និង ធ្វើចំណោលដោយ**

**នាយដ្ឋានស្ថិតិ**

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**